មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ: 01143/12/...../ម.ស.ម.ក/

សូមគោរពជូន

លោក បញ្ញា អន

ជំទួយការទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) និង

តំណាងកម្ពុជាប្រចាំគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស

(គ.អ.រ.អ.ស.ម)

កម្មវត្ថុ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្នើសុំកិច្ចពិភាក្សាជាបន្ទាន់អំពីសេចក្តីព្រាងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន

ខ្ញុំសរសេរលិខិតនេះជូនចំពោះលោកពាក់ព័ន្ធនឹងការដាក់ស្នើសុំឲ្យពិនិត្យសេចក្តីព្រាងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន ("ស.ស.ម.អ") នៅកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ ដែលនឹងប្រព្រឹត្តទៅនាពេលឆាប់ៗខាងមុខនៅក្នុងរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៨ ដល់ ២០ ខែវិច្ឆិកា ឆ្នាំ២០១២។ ខ្ញុំសូមសំដែងនូវក្តីបារម្ភយ៉ាងជ្រាលជ្រៅត្រង់ថានៅក្នុងតួនាទីរបស់លោកជាសមាជិកនៃក្រុមការងាររបស់កម្ពុជាក្នុងការតាក់តែងសេចក្តីព្រាង ស.ស.ម.អ លោកមិនបានស្វែងរកកិច្ចពិភាក្សាឲ្យបានស៊ីជម្រៅជាមួយនឹងសង្គមស៊ីវិលកម្ពុជា ឬ ទទួចសុំទិន្នន័យ ឬ មតិយោបល់ផ្សេងៗដែលទាក់ទងនឹង ស.ស.ម.អ។

មាត្រា១ នៃធម្មនុញ្ញអាស៊ាន ប្រទេសសមាជិកអាស៊ានទាំងអស់បានធ្វើសច្ចាប្រណិធានថានឹង៖ *"ជំរុញការយកចិត្តទុកដាក់ដល់ប្រជាជនអាស៊ាន ក្នុងនោះ គ្រប់ផ្នែកទាំងអស់នៃសង្គមត្រូវបានលើកទឹកចិត្តឲ្យចូលរួមនិងទទួលយកផលប្រយោជន៍ពីដំណើរការសមាហរណកម្ម និងការកសាងសហគមន៍អាស៊ាន។"* ខ្ញុំសូមរម្លឹកលោកដោយក្តីគោរពថា *"គ្រប់ផ្នែកទាំងអស់នៃសង្គម"* រួមបញ្ចូលទាំងអង្គការសង្គមស៊ីវិល តួយ៉ាងដូចជាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលធ្វើការមិនត្រឹមតែផ្តោតទៅលើប្រជាពលរដ្ឋតាមរយៈការចូលរួមក្នុងកិច្ចការពារ និងលើកស្ទួយសិទ្ធិមនុស្សប៉ុណ្ណោះទេ តែថែមទាំងខិតខំប្រឹងប្រែងចូលរួមនៅក្នុងកិច្ចដំណើរការសមាហរណកម្ម និងការកសាងសហគមន៍អាស៊ានក្នុងការគាំទ្រដល់រដ្ឋាភិបាលរបស់ខ្លួន និងការចូលរួមជាមួយនឹងក្រុមការងារសង្គមស៊ីវិលនៅតាមបណ្តាប្រទេសសមាជិកអាស៊ានដទៃទៀត។

កាលពីខែវិច្ឆិកា ឆ្នាំ២០១១ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស អ្នកស្រី កីឡៃ បានធ្វើសេចក្តីថ្លែងការណ៍ជាលើកដំបូងទៅកាន់គណៈកម្មការអន្តរដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស

អាសយដ្ឋាន ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩, សង្កាត់ចឹងក្របែក ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ២៥១៥, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ០២៣ ៧២៦ ៩០១ ទូរសារ: ០២៣ ៧២៦ ៩០២ អ៊ីមែល: info@cchrcambodia.org វេបសាយ: www.cchrcambodia.org

("គ.អ.រ.អ.ស.ម")។ ក្នុងអំឡុងពេលនៃសេចក្តីថ្លែងការណ៍របស់គាត់ អ្នកស្រី ភីឡៃ បានព្រមានជាមុនថា ភាពជោគជ័យរបស់ គ.អ.រ.អ.ស.ម នឹងត្រូវវិនិច្ឆ័យតាមរយៈសមិទ្ធិផលរបស់ខ្លួន ហើយកិច្ចការនឹងត្រូវយកទៅប្រៀបធៀបជាមួយនឹងស្ថាប័នតាមតំបន់ដទៃទៀត។ អ្នកស្រីបានជំរុញ គ.អ.រ.អ.ស.ម ឲ្យយកចិត្តទុកដាក់ចំពោះការស្នើទាំងឡាយអំពីតម្លាភាពទូលំទូលាយរបស់សង្គមស៊ីវិល ជាពិសេសពាក់ព័ន្ធនឹងការគាក់តែងសេចក្តីព្រាង ស.ស.ម.អ។ ការស្នើសុំទាំងនោះត្រូវបានធ្វើម្តងហើយម្តងទៀតនៅក្នុងឱកាសជាច្រើនទូទាំងសហគមន៍អាស៊ាន រួមទាំងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី មកទល់ពេលនេះមានតែក្រុមការងារគាក់តែងសេចក្តីព្រាងរបស់ប្រទេសថៃ និងឥណ្ឌូនេស៊ី ប៉ុណ្ណោះបានលើកឡើងថាពួកគេនឹងពិគ្រោះពិភាក្សាជាមួយនឹងសង្គមស៊ីវិល និងភ្នាក់ងារដៃគូជាតិផ្សេងទៀត។

នេះពិតជាមានក្តីបារម្ភសម្រាប់សង្គមស៊ីវិលកម្ពុជា ដោយរួមទាំង ម.ស.ម.ក ដោយហេតុថាសេចក្តីព្រាងរបស់ ស.ស.ម.អ ថ្មីៗនេះមិនប្រតិបត្តិតាមច្បាប់ និងបទដ្ឋានអន្តរជាតិឲ្យពេញលេញ។ អាចនឹងមានការវិវឌ្ឍន៍ដែលទទួលយកបាន ប្រសិនសេចក្តីពិស្តារនៃមន្ទិលសង្ស័យទាំងនេះអាចនឹងត្រូវបានលើកឡើងជាមួយលោក ក្នុងហានៈជាផ្លូវការរបស់លោកតាមរយៈកិច្ចពិភាក្សាស៊ីជម្រៅ និងកំណត់នូវចំណុចរួមគ្នា មុននឹងការដាក់ស្នើ ស.ស.ម.អ ឲ្យពិនិត្យនៅកិច្ចប្រជុំកំពូលនាពេលដ៏ឆាប់ខាងមុខ។ កិច្ចពិភាក្សាបែបនេះអាចនឹងធ្វើឲ្យរឹតតែប្រសើរឡើង និងមានភាពត្រឹមត្រូវចំពោះការពិភាក្សា និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់ គ.អ.រ.អ.ស.ម គួរតែផ្អែកលើគោលការណ៍នៃពិគ្រោះយោបល់ តម្លាភាព និងគណនេយ្យភាព ឲ្យដូចស្ថាប័នតំបន់ផ្សេងទៀតនាពេលអនាគត។ ប្រសិនជាកិច្ចពិភាក្សាមិនកើតមានឡើងទេនោះ ទំនងណាស់ដែលថាភាពត្រឹមត្រូវនៃ ស.ស.ម.អ នឹងនាំឲ្យមានចំណោទបញ្ហាក្នុងចំណោមការត្រួតពិនិត្យ និងការរិះគន់ខ្លាំងក្លាជាសាធារណៈ។

កាលពីខែមិថុនា ឆ្នាំ២០១២ ឯកឧត្តម បណ្ឌិត ឱម យិនទៀង តំណាងកម្ពុជា និងជាប្រធានដឹកនាំ គ.អ.រ.អ.ស.ម បានទទួលស្គាល់នូវសារៈសំខាន់នៃ ស.ស.ម.អ ដែល"*នឹងប៉ះពាល់អាយុជីវិតរបស់ប្រជាជនជាច្រើនលាននាក់ដែលរស់នៅក្នុងតំបន់អាស៊ាន*"។ ក្នុងហានៈជាប្រធានដឹកនាំ គ.អ.រ.អ.ស.ម ប្រទេសកម្ពុជាទទួលខុសត្រូវក្នុងការគោរពជាននអនុវត្តទិសដៅ និងស្មារតីនៃធម្មនុញ្ញអាស៊ាន និងស.ស.ម.អ។ ស្ថិតក្រោមក្រសែភ្នែករបស់ស្ថាប័នតំបន់ និងអន្តរជាតិទាំងអស់ ប្រទេសកម្ពុជាគប្បីក្រសោបយកកាលានុវត្តភាព ដើម្បីបង្ហាញស្មារតីគោរពការពិគ្រោះយោបល់ តម្លាភាព និងគណនេយ្យភាព ក្នុងគោលបំណងការពារ និងលើកស្ទួយសិទ្ធិមនុស្ស។

អាស្រ័យដូចបានរៀបរាប់ខាងលើ ខ្ញុំសូមជំរុញឲ្យលោកពិនិត្យពិចារណាចំពោះការអញ្ជើញសមាជិកនានារបស់បណ្តាអង្គការសង្គមស៊ីវិលកម្ពុជាឲ្យចូលរួមកិច្ចប្រជុំថ្នាក់ជាតិ ដែលអាចជាកិច្ចពិភាក្សាល្អិតល្អន់ទាក់

ទិននឹងការតាក់តែងសេចក្តីព្រាង ស.ស.ម.អ ដោយមានការពឹងទុកក្នុងការតាក់តែងឯកសារមួយដែលយ៉ាងហោចណាស់ក្នុងទស្សនៈវិស័យរបស់កម្ពុជា ជាឯកសារដែលតំណាងដ៏ត្រឹមត្រូវរបស់ប្រជាជន ក៏ដូចជាអត្ថប្រយោជន៍របស់ពួកគេ។ ខ្ញុំក៏សូមស្នើផងដែរឲ្យលោកបោះពុម្ពផ្សព្វផ្សាយសេចក្តីព្រាង ស.ស.ម.ក ចុងក្រោយមុនពេលមានកិច្ចប្រជុំណាមួយ ដើម្បីសម្រួលដល់កិច្ចពិភាក្សាឲ្យបានលទ្ធផលខ្ពស់។

ដោយសារតែកិច្ចប្រជុំកំពូលខិតជិតបំផុតហើយនោះ ខ្ញុំសូមស្វាគមន៍ដោយក្តីរីករាយបំផុតចំពោះការឆ្លើយតបភ្លាមៗរបស់លោក។

សូមលោកមេត្តាទទួលនូវក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២
ប្រធានស្តីទីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ចក់ សុភាព

<u>ចម្លងជូន៖</u>

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)
- ឯកឧត្តម បណ្ឌិត ឱម យិនទៀង (ទេសរដ្ឋមន្ត្រី និងប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(គ.ស.ម.ក) តំណាងកម្ពុជា និងប្រធានដឹកនាំ គ.អ.រ.អ.ស.ម)